# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Feb-2013, 13:58
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

## ចម្លើយតបទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញាចំពោះឯកសាររបស់មេធាវីការពារក្តី

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

Victor KOPPE
Joshua ROSESWEIG
Forest O'NEILL-GREENBERG
Sofie HOGESTOL
Renee DE GEUS

**ផ្ញើជូន៖**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង**

**លោក Andrew CAYLEY**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**
**Elisabeth SIMONNEAU-FORT**

មេធាវីការពារក្ដីជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្ដី") តទៅនេះសូមដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងការជំទាស់ដោយផ្ទាល់មាត់របស់សហព្រះរាជអាជ្ញា ចំពោះឯកសារ E131/1/13.11[1] ដែលធ្វើឡើងក្នុងអំឡុងពេលសវនាការដេញដោលលើឯកសារកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣[2]។

១. កាលពីខែមករា ឆ្នាំ២០១៣ ក្រុមមេធាវីការពារក្ដីបានស្នើសុំឱ្យដាក់ឯកសារជាច្រើននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង រួមទាំងឯកសារ E131/1/13.11 ផងដែរ[3]។ អង្គជំនុំជម្រះបានដាក់ឯកសារ E131/1/13.11 នៅក្នុងសំណុំរឿង និងបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងសម្រេចនៅពេលក្រោយ បើសិនជាឯកសារនេះបំពេញបានលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ជាកម្មវត្ថុនៃការជំទាស់ពីភាគី[4]។ នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានជំទាស់ដោយផ្ទាល់មាត់ទៅនឹងឯកសារ E131/1/13.11 ក្នុងអំឡុងពេលសវនាការដេញដោលរបស់អង្គជំនុំជម្រះលើភាពអាចទទួលយកបាននៃឯកសារ[5]។ សហព្រះរាជអាជ្ញាបានលើកអំណះអំណាងថាពុំមាន "ទំនាក់ទំនងដោយផ្ទាល់" រវាងព័ត៌មាននៅក្នុងឯកសារនេះ និង "ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យកាលកម្ពុជានោះទេ ហើយហេតុដូច្នេះ

[1] ឯកសារ E-131/1/13.11 "សាធារណរដ្ឋប្រជាមានិតកម្ពុជា ឯករាជ សន្តិភាព សេរីភាព និង សុភមង្គល" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៨៦ ERN 00773822-00773831.

[2] សូមមើលឯកសារ E-1/161.1 "ប្រតិចារិតសវនាកាលើអង្គសេចក្ដី" ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣, ERN 00882521-00882613, p.20:15-19 និង pp. 25:14-26:5

[3] សូមមើលឯកសារ សារ E-131/1/13.1 "ឧបសម្ព័ន្ធ: បញ្ជីឯកសារនានាដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលដំណាក់ដំបូងនៃការជំនុំជម្រះ" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ ERN 00774395-00774403 នៅទំព័រ៩ (លេខ៣៥)។

[4] សូមមើលឯកសារ សារ E-190 "សេចក្ដីសម្រេចទាក់ទងនឹងឯកសារថ្មី និងបញ្ហាដែលពាក់ព័ន្ធដទៃទៀត" ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ERN 00804367-00804382, នៅកថាខណ្ឌ៣៧ ។

[5] សូមមើលឯកសារ E-1/161.1 "ប្រតិចារិតសវនាកាលើអង្គសេចក្ដី" ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣, ERN 00882521-00882613, p. 20:15-19 and pp.25:14-26:5 ។

ឯកសារនេះមិនពាក់ព័ន្ធ[6]។ នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានបង្គាប់ដល់ភាគី ថាមេធាវីការពារក្តីអាចដាក់សារណាជាលាយលក្ខណ៍អក្សរទាក់ទងនឹងការទទួលយកជាភស្តុតាងនៃឯកសារនេះឲ្យបានត្រឹមថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣[7]។

២. អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង សម្ភារៈអាចទទួលយកជាភស្តុតាង បើសិន (i) ជាប់ពាក់ព័ន្ធ ឬ មិនជាការស្នើសុំជាន់គ្នា (ii) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ (iii) សមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង (iv) ច្បាប់មិនអនុញ្ញាត និង(v) មិនមានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬ មានប្រយោជន៍ដល់កិច្ចដំណើរការនិតីវិធី[8]។ ឯកសារ E131/1/13.11 បានបំពេញលក្ខណៈវិនិច្ឆ័យទាំងអស់។

៣. ឯកសារ E131/1/13.11 គឺជារបាយការណ៍របស់សារធារណប្រជាមានិតកម្ពុជាទៅក្រុមប្រឹក្សារដ្ឋមន្ត្រី "ស្តីពីផែនការ **ក-៥** សម្រាប់ឆ្នាំសារពើព័ន្ធ១៩៨៧" ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៨៦[9]។ ដូចដែលបានបង្ហាញដោយចំណងជើងរ របាយការណ៍កម្រាស់១០ទំព័រលម្អិតអំពីផែនការកសាងសម្រាប់គំរាង ក-៥ និងរួមបញ្ចូលទាំងការពន្យាករលម្អិតនូវចំនួនកំលាំងពលកម្មដែលត្រូវការ ដើម្បីអនុវត្តផែនការនេះ បន្ថែមពីលើការពិពណ៌នានៃរចនាសម្ព័ន្ធនានាដែលត្រូវស្ថាបនាផងដែរ[10] ។

---

[6] សូមមើលឯកសារ E-1/161.1 "ប្រតិចារិតសវនាការលើអង្គសេចក្តី" ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣, ERN 00882521-00882613, p. 20:15-19 ។

[7] សូមមើលឯកសារ E-1/162.1 "ប្រតិចារិតសវនាការលើអង្គសេចក្តី" ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣, ERN 00883761-00883840, p. 68:15-20

[8] វិធាន៨៧(៣) ។

[9] សូមមើលឯកសារ សារ E-131/1/13.11 "សាធារណរដ្ឋប្រជាមានិតកម្ពុជា ឯករាជ សន្តិភាព សេរីភាព និងសុភមង្គល" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៨៦ ERN 00773822-00773831 នៅទំព័រ១។

[10] សូមមើលឯកសារ សារ E-131/1/13.11 "សាធារណរដ្ឋប្រជាមានិតកម្ពុជា ឯករាជ សន្តិភាព សេរីភាព និងសុភមង្គល" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៨៦ ERN 00773822-00773831 នៅទំព័រ៧ដល់១០។

៤. ផែនការ **ក-៥** គឺជាគម្រោងកសាងដ៏ធំមួយដែលផ្តួចផ្តើមឡើងដោយសារធារណរដ្ឋប្រជាមានិតកម្ពុជាដែលមានរយៈពេលពីឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៨៨[11]។ ហ៊ុន ឈុនលី អ្នកនិពន្ធសៀវភៅដែលមានចំណងជើងថា "ជីវិតរបស់គ្រូពេទ្យម្នាក់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ" និងបានផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះសាលាដំបូង បានពិពណ៌នាផែនការ ក-៥ នៅក្នុងសៀវភៅរបស់គាត់ដូចខាងក្រោម:

> ព្រឹត្តិការណ៍ដ៏សោកនាដកម្មមួយទៀតកើតឡើងនៅឆ្នាំ១៩៨២។ វាគឺជាផែនការយុទ្ធសាស្ត្រ ក-៥ ដ៏ទុសយ៍ដែលមានរយៈពេលយូរជាងរបបកម្ពុជាកម្ពុជាធិបតេយ្យដល់ទៅពីរដង និង*បានឆក់យកជីវិតប្រជាជនរាប់រយពាន់នាក់នៅទូទាំងប្រទេស....*។ ប្រជាជនជាច្រើននាក់ស្លាប់ ឬរងរបួសដោយសារគ្រាប់មីន ដោយគ្រោះថ្នាក់ពីការធ្វើការ និងស្លាប់ដោយជំងឺគ្រុនចាញ់។ មន្ទីរពេទ្យនៅខេត្តបាត់ដំបងមានអ្នកជំងឺណែនណាប់ដែលពួកគេភាគច្រើនដេកផ្ទាល់នឹងកម្រាល ការ៉ូ និងរបៀង។ នាពេលនៅឆ្នាំ១៩៨៤ មន្ទីរពេទ្យនៅខេត្តបាត់ដំបងមានអ្នកជំងឺណែនណាប់ អ្នកជំងឺមានចំនួនលើសពីមួយពាន់នាក់។ បុគ្គលិកមន្ទីរពេទ្យរុញគ្រែទាំងអស់ទៅខាងក្រៅនៅក្រោមដើមឈើក្នុងទីធ្លាមន្ទីរពេទ្យ។ អ្នកជំងឺដេកផ្ទាល់នឹងកម្រាលការ៉ូ របៀង និងនៅលើគ្រែក្រោមដើមឈើ[12]។

៥. ក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់ ហ៊ុន ប៊ុនលី នៅចំពោះមុខអង្គជំនុំជម្រះ មេធាវីការពារ នួន ជា ព្យាយាមសាកសួរសាក្សីនេះទាក់ទងនឹងសម្រង់នេះ។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលើក

---

[11] សូមមើលឯកសារ D-313/1.2.8 "ជីវិតរបស់គ្រូពេទ្យម្នាក់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ" ខែមិនា ឆ្នាំ២០០៨ ERN: 00369669- 003696820 នៅទំព័រ១៣៨។

[12] សូមមើលឯកសារ D-313/1.2.8 "ជីវិតរបស់គ្រូពេទ្យម្នាក់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ" ខែមិនា ឆ្នាំ២០០៨ ERN: 00369669- 003696820 នៅទំព័រ១៣៨-១៣៩។

សំណួរដោយមូលហេតុថាវាពាក់ព័ន្ធនឹងអង្គហេតុនៅក្រៅយុត្តាធិការពេលវេលារបស់ អវតក ខាងក្រោមនេះគឺជាការលើកឡើង:

**លោក PAUW:**

នៅក្នុងឯកសារ D140/1/1 គឺជាស្ថិតិ--ស្តីពីចំនួនប្រជាជន នៅក្នុងនោះបាននិយាយថា ទិន្នន័យទាក់ទងនឹងការកំណត់ផ្នូររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺបង្ហាញអំពីជនរងគ្រោះនៅក្នុងសម័យខ្មែរក្រហម ហើយទិន្នន័យទាំងនេះ គឺមិនមាន--មិនត្រឹមតែមានប្រយោជន៍ដែរនោះទេ គឺត្រូវតែធ្វើឡើងដែរ។ វាបង្ហាញយ៉ាងច្បាស់ថាជនរងគ្រោះភាគច្រើននៅក្នុងផ្នូររួមនោះ ទោះបីមិនទាំងអស់ក៏ដោយ គឺជាជនរងគ្រោះខ្មែរក្រហម។ នៅក្នុងរបាយការណ៍នោះផងដែរ ក៏បានលើកឡើងផងដែរ គេមិនបានដឹងថាមានហេតុការណ៍ផ្សេងកើតឡើងនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលនាំឲ្យមានការកាប់សម្លាប់ ឬការស្លាប់មនុស្សច្រើនដូចផងដែរ។ ដូច្នេះវាគឺពាក់ព័ន្ធទៅនឹងបញ្ហាផែនការ ក៥ ដែលមានមនុស្សស្លាប់រាប់ពាន់នាក់។ ក៥ ជាពិសេសកើតឡើងនៅម្តុំបាត់ដំបង ដោយសារហេតុនេះហើយវាទំនងដែលថា ប្រជាជនដែលបានស្លាប់នៅក្នុងគ្រោងផែនការ ក៥ នោះក៏ត្រូវបានគេយកទៅកប់ក្នុងផ្នូររួមនោះដែរ។ ដោយសារតែមានមនុស្សរាប់រយពាន់នាក់នៅពេលនោះបានស្លាប់។ វាគឺជាសំណួរមួយពាក់ព័ន្ធផងដែរថា តើសាក្សីនោះបានដឹងថាជនរងគ្រោះនៅក្នុងគម្រោងផែនការ ក៥ នោះត្រូវបានគេយកទៅកប់នៅក្នុងផ្នូររួមនោះ រួមជាមួយដែរឬទេ? ជាពិសេសនៅម្តុំក្រុងបាត់ដំបង។ ហេតុដូច្នេះហើយវាជាសំណួរមួយដែលមានសំខាន់ ទោះបីវានៅក្រៅវិសាលភាពនៃយុត្តាធិការរបស់អង្គជំនុំជម្រះក៏ដោយ ជាពិសេសវាមានហេតុផល--

**ប្រធានអង្គជំនុំជម្រះ**

អត់ចាំបាច់ឆ្លើយតបទេសាក្សី ពីព្រោះមេធាវីការពារបានបញ្ជាក់ខ្លួនឯងច្បាស់ហើយជាសំណួរក្រៅវិសាលភាពនៃអង្គជំនុំជម្រះកំណត់ធ្វើសវនាការ គឺជាវិសាលភាពដែលសម្តត្ថកិច្ច អវតក រួចទៅហើយ។

**លោក PAUW:**

ខ្ញុំសូមឲ្យអង្គជំនុំជម្រះបង្ហាញនូវហេតុផលមួយឲ្យបានច្បាស់លាស់ ដែលខ្ញុំនៅពេលនេះអះអាងថាមានជនរងគ្រោះរាប់រយពាន់នាក់ មិនត្រូវបានសម្លាប់ដោយខ្មែរក្រហមនោះទេ។ ក៏ប៉ុន្តែមានជនរងគ្រោះរាប់សែននាក់ដែលត្រូវបានសម្លាប់ដោយផែនការក៥។ ដូច្នេះ វាជាភស្តុតាងមួយដោះបន្ទុក ដែលខ្ញុំចង់សួរជជីកទៅលើបញ្ហានេះ។ ហើយទោះបីជាវាមិនស្ថិតនៅក្នុងយុត្តាធិការពេលវេលាក៏ដោយ ខ្ញុំសូមលើកឡើងចំណុចនេះ ដោយគោរពអង្គជំនុំជម្រះ

**ប្រធានអង្គជំនុំជម្រះ**

យើងបានស្តាប់លោកនិយាយដោយខ្លួនឯង។ បង្ហាញដោយខ្លួនឯង វាក្រៅវិសាលភាពនៃដែនសមត្ថកិច្ចរបស់ អវតក។ នេះជាបញ្ហាយ៉ាងច្បាស់លាស់រួចទៅហើយ ហើយអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការទេ។ នៅក្នុងនោះ គឺអង្គជំនុំជម្រះបានកំណត់ធ្វើសវនាការដេញដោលទៅលើអង្គហេតុលើវិសាលភាពក្នុងសំណុំរឿង ០០២/០១។ ដោយឡែកសាក្សីនេះ គឺមានការពាក់ព័ន្ធទៅលើអង្គហេតុពីរសំខាន់ គឺអនុវត្តគោលនយោបាយជម្លៀស ហើយនិងរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន។ យើងបានប្រាប់តាំងពីព្រឹក តាំងពីដើមដំបូងនៃការដំណើរការស្តាប់សក្ខីកម្មដើម--ប្រគល់វេទិការទៅតាំងសំណួរដេញដោល គឺយើងបានកំណត់អំពីវិសាលភាពនៃការដែលដឹង ដែលអង្គហេតុដែលអាចពាក់ព័ន្ធ ហើយយើងបានដំណើរការប្រព្រឹត្តទៅនៃ ការដេញដោលចំពោះសាក្សីនេះ។ អ៊ីញ្ចឹងវាមានទាំងពីរ ទាំងវិសាលភាពនៅក្នុង អវតក ទាំងវិសាលភាពនៅក្នុងសំណុំរឿង ០០២/០១ ទាំងវិសាលភាពនៃសាក្សី ដែលកំណត់ឲ្យធ្វើសវនាការនេះបានដឹងនូវអង្គហេតុដែលខ្លួនមានសមត្ថភាពអាចឆ្លើយ បំភ្លឺចំពោះមុខអង្គសវនាការបាន។

**លោក PAUW:**

លោកប្រធាន ខ្ញុំនឹងបន្តទៅមុខទៀត ខ្ញុំគ្រាន់តែចង់លើកឡើងនៅក្នុងប្រតិចារិតគឺសាក្សីរូបនេះក៏បានដឹងអំពីហេតុការណ៍ផងដែរ។

**ប្រធានអង្គជំនុំជម្រះ**

បាទ សូមអញ្ជើញ! បើសិនជាអស់សំណួរលោកអាចប្រគល់វេទិកាទៅឱ្យមេធាវីទៀតបាន។

**លោក PAUW:**

ខ្ញុំនឹងចូលសួរទៅដល់ប្រធានបទមួយផ្សេងទៀត ទោះបីជាខ្ញុំមិនអាចមានឱកាសសួរអំពីភស្តុតាងដោះបន្ទុកនេះក៏ដោយ ។

៦. ដូចដែលមេធាវីការពារក្តីបានវែកញែកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចមកហើយថា របាយការណ៍របស់បណ្ឌិត Tabeau ដែលសហព្រះរាជអាជ្ញាសុំឱ្យទទួលយកជាភស្តុតាង ហើយដែលឥឡូវនេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ[13] គឺផ្អែកទៅលើការសន្មតទុកជាមុនយ៉ាងច្បាស់ក្រឡែតដែលថា គ្មានផ្នូររួមណាមួយក្នុងប្រទេសកម្ពុជាកើតចេញពីប្រភពផ្សេងក្រៅពីពួកខ្មែរក្រហមឡើយ។ បណ្ឌិត Tabeau សន្និដ្ឋានថា "និយាយជារួម វាពិតជាមិនទំនង ហើយជាក់ស្តែងវាមិនអាចទៅរួចទេដែលថា ផ្នូររួមដែលមានក្នុងផែនទីមកទល់ពេលនេះ និងបំណែកសាកសពក្នុងរណ្តៅសពរួមទាំងនោះ អាចជាប់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ផ្សេងក្នុងប្រវត្តិសាស្ត្រកម្ពុជាដែលគ្មានវត្តមានខ្មែរក្រហម[14]"។

៧. ដូច្នេះ ការលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទងនឹងអង្គហេតុដែលថាគ្មានរណ្តៅសពរួមណាមួយក្នុងប្រទេសកម្ពុជាមិនជាប់ពាក់ព័ន្ធនឹងខ្មែរក្រហមនោះ គឺជាការលើកឡើងតាមសំណើរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ ភស្តុតាងណាមួយដែលផ្ទុយ ឬជំទាស់ទៅនឹងការលើកឡើងបែបនេះ គឺច្បាស់ជាពាក់ព័ន្ធ។ សៀវភៅរបស់បណ្ឌិតឈុនលី គឺបានដាក់

---

[13] សូមមើលឯកសារ **E-185/1.3** "ឧបសម្ព័ន្ធ គ-ឯកសារស្នើឡើងដោយសហព្រះរាជអាជ្ញា" ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២, ERN 00884447-00884623 (របាយការណ៍បណ្ឌិត Tabeau), ទំព័រទី៥។

[14] សូមមើលរបាយការណ៍បណ្ឌិត Tabeau ទំព័រ១៧ (នៃរបាយការណ៍គោល)។

នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ[15] ហើយវាគឺជាភស្តុតាងជំទាស់មួយយ៉ាងច្បាស់ក្រឡែត ដោយព្យាយាមបញ្ជាក់ឲ្យឃើញថា រណ្តៅសពរួមដែលមិនជាប់ពាក់ព័ន្ធនឹងខ្មែរក្រហម ពិតជាមាននៅក្នុងប្រទេសកម្ពុជា។ ឯលសារ E131/1/13.11 ជាឯកសារក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលពាក់ព័ន្ធនឹងផែនការ ក-៥ ហើយបានផ្តល់ព័ត៌មានគាំទ្រដល់អត្ថិភាពនៃផែនការក-៥ ដូច្នេះឯកសារនេះបានបង្កើនតំលៃជាភស្តុតាងនៃការអះអាងរបស់បណ្ឌិត ឈុនលី។

៨. ដូចបណ្ឌិត Tabeau ខ្លួនគាត់ផ្ទាល់បានគូសបញ្ជាក់ថាសារៈសំខាន់នៃឯកសារ E131/1/13.11 មិនទាន់ដល់ចំណុចកំពូលនៅឡើយទេ ព្រោះផែនទីរណ្តៅសពរួមដែលគាត់ប្រើនោះគឺមិនបានផ្អែកលើ កោសល្យវិច្ច័យផ្នែកវិជ្ជាសាស្ត្រ ឬកោសល្យវិច្ច័យដោយផ្ទាល់លើរណ្តៅសពរួមដែលគាត់បានចងក្រងទុកជាឯកសារឡើយ[16]។ ផ្ទុយទៅវិញ ការសន្និដ្ឋានរបស់គាត់លើបញ្ហានេះគឺជាការសន្និដ្ឋានដែលមិនគ្រប់ជ្រុងជ្រោយ។ ដូច្នេះ ភស្តុតាងរបស់បណ្ឌិត ឈុនលី មិនត្រឹមតែជាភស្តុតាងបឋម (*prima facie*) ដែលមិនស៊ីសង្វាក់គ្នាទៅនឹងការអះអាងគាំទ្របាយការណ៍របស់បណ្ឌិតTabeau ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជាភស្តុតាងដ៏គួរឲ្យជឿជាក់ថែមទៀតផង។

៩. នៅចុងបញ្ចប់ ដោយសារតែការទទួលយកឯកសារ E131/1/13.11 ជាភស្តុតាង នឹងមានន័យថាប្រជាជនបានស្លាប់ក្នុងក្នុងរបបខ្មែរក្រហម មានចំនួនតិចជាងអ្វីដែលបានបញ្ជាក់ក្នុងរបាយការណ៍របស់បណ្ឌិត Tabeau (ប្រហែលតាមរយៈការរាប់ចំនួនប្រជាជនរាប់លាននាក់បើតាមលោក ឈុនលី) នោះវាមិនត្រឹមតែជាភស្តុតាងពាក់ព័ន្ធទៅនឹងនីតិវិធីប៉ុណ្ណោះទេ[17] ប៉ុន្តែថែមទាំងជាភស្តុតាងដោះបន្ទុកទៀតផង។

---

[15] សូមមើលឯកសារ **E-185/1.3** "ឧបសម្ព័ន្ធ គ-ឯកសារស្នើឡើងដោយសហព្រះរាជអាជ្ញា" ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២, ERN 00884447-00884623, ទំព័រទី១២៣។

[16] របាយការណ៍បណ្ឌិត Tabeau, ទំព័រទី១២ (នៃរបាយការណ៍គោល)។

[17] បញ្ហាទាក់ទងនឹងចំនួនច្បាស់លាស់នៃជនរងគ្រោះក្នុងរបបខ្មែរក្រហមគឺមិនពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១ឡើយ។ ដោយផ្អែកលើការសន្និដ្ឋានបែបនេះ របាយការណ៍បណ្ឌិត Tabeauគឺមិនពាក់ព័ន្ធ។ ប្រសិនបើរបាយការណ៍បណ្ឌិត Tabeau ត្រូវបានទទួលយកជាភស្តុតាង នោះភស្តុតាងដែលប្រឆាំងនឹងវាដោយផ្ទាល់ក៏ត្រូវបានទទួលយកផងដែរ។

១០. ឯកសារ E131/1/13.11 បានបំពេញលក្ខខណ្ឌតម្រូវទាំងអស់ក្នុងវិធាន៨៧(៣) ។ ឯកសារ E131/1/13.11 គឺពាក់ព័ន្ធ ហើយជាឯកសារដើមដែលបានបង្ហាញលម្អិតអំពីអង្គហេតុដែលមិនទាន់មាននៅក្នុងសំណុំរឿង ហើយវាក៏មិនមែនជាឯកសារច្រំដែលដែរ។ សម្រាប់ហេតុផលស្រដៀងគ្នានេះ ឯកសារE131/1/13.11 មិនមែនជាឯកសារខុសកាលៈទេសៈ ហើយក៏មិនមានបំណងពន្យាពេលនីតិវិធីដែរ។ ផ្ទុយទៅវិញវាគឺជាឯកសារដ៏សាកសម "ដើម្បីបញ្ជាក់ពីការពិតដែលវាចង់បញ្ជាក់"។ ដូច្នេះ គ្មានមូលហេតុផ្សេងទៀតតាមផ្លូវច្បាប់ដែលមិនអនុញ្ញាតឲ្យទទួលយកឯកសារ E131/1/13.11 ជាភស្តុតាងឡើយ។

១១. អាស្រ័យដូចបានបញ្ជាក់ក្នុងមូលហេតុខាងលើ មេធាវីការពារក្តីសូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារ E131/1/13.11 ជាភស្តុតាង។

**សហមេធាវីការពារក្តីអន្តរជាតិ នួន ជា**

Victor KOPPE